# សេចក្តីស្រឡាញ់ និងច្បាប់

អែលឌើរដាល្លិន អេក អូក
នៃក្រុមនៃពួកសាវកដប់ពីរនាក់

*សេចក្តីស្រឡាញ់នៃព្រះមិនយកមកជំនួសក្រិត្យវិន័យ និងបទបញ្ញត្តិរបស់ទ្រង់ទេ ហើយប្រសិទ្ធភាពនៃក្រិត្យវិន័យ និងបទបញ្ញត្តិរបស់ព្រះក៏មិនកាត់បន្ថតគោលបំណង និងប្រសិទ្ធភាពនៃសេចក្តីស្រឡាញ់របស់ទ្រង់ដែរ ។*

ខ្ញុំបានចាប់អារម្មណ៍ចង់និយាយអំពីសេចក្តីស្រឡាញ់របស់ព្រះ និងបទបញ្ញត្តិរបស់ព្រះ។ សារលិខិតរបស់ខ្ញុំគឺថា សេចក្តី-ស្រឡាញ់ជាសាកល ហើយល្អឥតខ្ចោះរបស់ព្រះ គឺត្រូវបានបង្ហាញនៅក្នុងគ្រប់ពរជ័យ នៃផែនការដ៏ល្អរបស់ទ្រង់ រួមមានទាំងភាពពិតថា ពរជ័យដ៏ជំរើសបំផុតរបស់ទ្រង់ ត្រូវបានរក្សាទុកសំរាប់អ្នកទាំងឡាយណា ដែលគោរពតាមក្រិតវិន័យរបស់ទ្រង់ ។1 ទាំងនេះគឺជាគោលការណ៍ដ៏អស់កល្បជានិច្ច ដែលគួរតែដឹកនាំឪពុកម្តាយនៅក្នុងសេចក្តីស្រឡាញ់ និងបង្រៀនកូនចៅរបស់ពួកគេ ។

I.

ខ្ញុំចាប់ផ្តើមជាមួយនឹងគំរូចំនួនបួនចំណុច ដែលបង្ហាញអំពីការភាន់ច្រឡំខ្លះៗក្នុងជីវិតរមែងស្លាប់រវាងសេចក្តីស្រឡាញ់ និងច្បាប់ ។

- មនុស្សវ័យក្មេងរស់នៅជាមួយដៃគូដោយមិនរៀបការម្នាក់ បានប្រាប់ដល់ឪពុកម្តាយដែលមានទុក្ខព្រួយថា "បើសិនជាលោកទាំងពីរពិតជាស្រឡាញ់ខ្ញុំ នោះលោកនឹងទទួលយកកូន និងដៃគូរបស់កូនដូចជាលោកទទួលយកកូនចៅដែលបានរៀបការរបស់លោកផងដែរ" ។

- យុវវ័យម្នាក់មានប្រតិកម្មចំពោះបញ្ហា ឬសម្ពាធរបស់ឪពុកម្តាយដោយប្រកាសថា "បើសិនជាលោកទាំងពីរ ពិតជាស្រឡាញ់កូន នោះលោកទាំងពីរនឹងមិនបង្ខំដល់កូនទេ" ។

នៅក្នុងឧទាហរណ៍ទាំងនេះ បុរសម្នាក់ដែលកំពុងតែល្មើសនឹងបទបញ្ញត្តិទាំងឡាយ ដោយពោលអះអាងថា សេចក្តីស្រឡាញ់របស់ឪពុកម្តាយ គួរតែទាត់ចោលនូវបទបញ្ញត្តិទាំងឡាយនៃក្រិត្យវិន័យរបស់ព្រះ និងការបង្រៀនរបស់ឪពុកម្តាយ ។

ឧទាហរណ៍ចំនួនពីរទៀត បង្ហាញអំពីការភាន់ច្រឡំក្នុងជីវិតរមែងស្លាប់ អំពីប្រសិទ្ធភាពនៃសេចក្តីស្រឡាញ់របស់ព្រះ ។

- បុរសម្នាក់បដិសេធគោលលទ្ធិ ដែលគួរស្វាមីភរិយាត្រូវតែបានរៀបអាពាហ៍ពិពាហ៍សំរាប់ភាពអស់កល្បជានិច្ច ដើម្បីឱ្យមានចំណងគ្រួសារីករាយនៅក្នុងជីវិតបន្ទាប់ គាត់បានប្រកាសថា "បើសិនជាព្រះពិតជាស្រឡាញ់យើង ខ្ញុំមិនជឿថា ទ្រង់នឹងបំបែកស្វាមី និងភរិយាតាមរបៀបនេះទេ" ។

- មនុស្សម្នាក់ទៀតនិយាយថាសេចក្តីជំនឿរបស់គាត់ត្រូវបានបំផ្លាញដោយសារការរងទុក្ខ ដែលព្រះអនុញ្ញាតឱ្យមានការរងទុក្ខមកលើមនុស្ស ឬជាតិសាសន៍មួយ គាត់សន្និដ្ឋានថា "បើសិនជាមានព្រះដែលស្រឡាញ់យើងពិតមែន នោះទ្រង់នឹងមិនទុកឱ្យរឿងនេះកើតឡើងដូច្នេះទេ" ។

មនុស្សទាំងនេះមិនជឿលើក្រិត្យវិន័យដ៏អស់កល្បជានិច្ចទេ ដែលពួកគេគិតថាជំទាស់ទៅនឹងគតិរបស់ពួកគេអំពីប្រសិទ្ធភាពនៃសេចក្តីស្រឡាញ់របស់ព្រះ។ មនុស្សដែលមានស្ថានភាពនេះ មិនយល់អំពីលក្ខណៈនៃសេចក្តីស្រឡាញ់របស់ព្រះ ឬគោលបំណងនៃក្រិត្យវិន័យ និងបទបញ្ញត្តិរបស់ទ្រង់ទេ។ សេចក្តីស្រឡាញ់របស់ព្រះមិនយកមកជំនួសក្រិត្យវិន័យ និងបទបញ្ញត្តិរបស់ទ្រង់ទេ ហើយប្រសិទ្ធភាពនៃក្រិត្យវិន័យ និងបទបញ្ញត្តិរបស់ព្រះ ក៏មិនកាត់បន្ថយគោលបំណង និងប្រសិទ្ធភាពនៃសេចក្តីស្រឡាញ់របស់ទ្រង់ដែរ។ វាមានលក្ខណៈពិតដូចគ្នាទៅនឹងសេចក្តីស្រឡាញ់ និងច្បាប់ របស់ឪពុកម្តាយ។

II.

ទីមួយ ចូរពិចារណាអំពីសេចក្តីស្រឡាញ់របស់ព្រះ បានពិពណ៌នាយ៉ាងមានអត្ថន័យនៅព្រឹកនេះ ដោយប្រធាន ឌៀថើរ អេស្វ អុជដូហ្វ។ សាវកប៉ុលបានសួរថា "តើអ្នកណានឹងពង្រាត់យើងចេញពីសេចក្តីស្រឡាញ់របស់ផងព្រះគ្រីស្ទបាន?"។ គ្មានសេចក្តីទុក្ខលំបាក គ្មានការបៀតបៀន គ្មានសេចក្តីអន្តរាយ ឬដាវ (សូមមើល រ៉ូម 8:35)។ គាត់បានបញ្ជាក់ថា "ត្បិតខ្ញុំជឿជាក់ថា ទោះស្លាប់ ឬរស់ ពួកទេវតា ឬអំណាចអ្វី...ឬរបស់អ្វីដែលកើតមកឯទៀតក្តី នោះពុំអាចនឹងពង្រាត់យើង ចេញពីសេចក្តីស្រឡាញ់របស់ព្រះបានឡើយ" (ខ. 38--39)។

គ្មានភស្តុតាងអំពីអំណាច និងភាពឥតខ្ចោះគ្មានព្រំដែននៃសេចក្តីស្រឡាញ់របស់ព្រះណាមួយអស្ចារ្យជាងភស្តុតាង ដូចដែលត្រូវបានប្រកាសដោយសាវកយ៉ូហានថាៈ "ត្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោកដល់ម្ល៉េះ បានជាទ្រង់ប្រទាន ព្រះរាជបុត្រាទ្រង់តែមួយ" (យ៉ូហាន 3:16)។ សាវកម្នាក់ទៀតបានសរសេរថា ព្រះ "មិនដែលបានសំចៃទុកនូវព្រះរាជបុត្រាទ្រង់បង្កើត គឺបានបញ្ជូនទ្រង់ទៅជំនួសយើងរាល់គ្នា" (រ៉ូម 8:32)។ ចូរគិតមើលថា តើព្រះវរបិតាសួគ៌របស់យើងមានទុក្ខប៉ុណ្ណា ដែលត្រូវបញ្ជូនព្រះរាជបុត្រារបស់ទ្រង់ឱ្យមកស៊ូទ្រាំនឹងការរងទុក្ខដែលមិនអាចថ្លែងបានសំរាប់អំពើបាបរបស់យើងនោះ។ នេះគឺជាភស្តុតាងដ៏អស្ចារ្យបំផុតអំពីសេចក្តីស្រឡាញ់របស់ទ្រង់សំរាប់យើងម្នាក់ៗ!

សេចក្តីស្រឡាញ់របស់ព្រះចំពោះកូនចៅរបស់ទ្រង់ គឺមានពិតដ៏នៅអស់កល្បជានិច្ច ប៉ុន្តែហេតុអ្វីបានជាទ្រង់ស្រឡាញ់យើងខ្លាំងម្ល៉េះ ហើយហេតុអ្វីបានជាយើងចង់បានសេចក្តីស្រឡាញ់នោះ? ចម្លើយគឺមាននៅក្នុងទំនាក់ទំនងរវាងសេចក្តីស្រឡាញ់របស់ព្រះ និងក្រិត្យវិន័យរបស់ទ្រង់។

មនុស្សមួយចំនួនហាក់ដូចជាឱ្យតម្លៃចំពោះសេចក្តីស្រឡាញ់របស់ព្រះ ដោយសារតែពួកគេសង្ឃឹមថា សេចក្តីស្រឡាញ់ដ៏មហិមា និងគ្មានលក្ខខណ្ឌរបស់ទ្រង់ នឹងលើកទោសពួកគេដោយក្តីមេត្តាករុណា ដោយមិនចាំបាច់គោរព ដល់ក្រិត្យវិន័យរបស់ទ្រង់ទេ។ ផ្ទុយទៅវិញអ្នកទាំងឡាយ ដែលយល់អំពីផែនការរបស់ព្រះសំរាប់កូនចៅរបស់ទ្រង់ដឹងថា ក្រិត្យវិន័យរបស់ព្រះ គឺមិនប្រែប្រួលទេ ហើយភាពពិតនេះ គឺជាភស្តុតាងដ៏មហិមាមួយទៀតនៃសេចក្តីស្រឡាញ់របស់ព្រះចំពោះកូនចៅរបស់ទ្រង់។ សេចក្តីមេត្តាករុណាពុំអាចកោងសេចក្តីយុត្តិធមិបានទេ2 ហើយអ្នកទាំងឡាយដែលទទួលបានសេចក្តីមេត្តាករុណាគឺ "កាន់តាមសេចក្តីសញ្ញា ហើយគោរពតាមព្រះបញ្ញត្តិ" (គ. និង ស. 54:6)។

យើងអានម្តងហើយម្តងទៀតនៅក្នុងព្រះគម្ពីរបរិសុទ្ធ និងព្រះគម្ពីរសម័យទំនើបអំពីការពិរោធរបស់ព្រះជាមួយនឹងពួកទុច្ចរិត3 និងការបង្ហាញសេចក្តីក្រោធរបស់ទ្រង់4 ទាស់នឹងពួកអ្នកដែលមិនគោរពដល់ក្រិត្យវិន័យរបស់ទ្រង់។ តើការពិរោធ និងសេចក្តីក្រោធជាភស្តុតាងនៃសេចក្តីស្រឡាញ់របស់ទ្រង់ ដោយរបៀបណា? យ៉ូសែបស្ម៊ីធ បានបង្រៀនថាព្រះ "[បាន] តាំងក្រិត្យវិន័យឡើងដើម្បីឱ្យ [តាមវិញ្ញាណដែលទ្រង់បានបញ្ជូនមក កាន់ពិភពលោក] អាចមានឯកសិទ្ធិមួយដើម្បីរីកចំរើនក្លាយដូចជាទ្រង់"។ 5 សេចក្តីស្រឡាញ់របស់ព្រះ គឺល្អឥតខ្ចោះណាស់ រហូតដល់ទ្រង់បានតំរូវដោយក្តីស្រឡាញ់ឱ្យយើងគោរពតាមបទបញ្ញត្តិទាំងឡាយរបស់ទ្រង់ ពីព្រោះទ្រង់ដឹងថា មានតែតាមការគោរពប្រតិបត្តិចំពោះក្រិតវិន័យរបស់ទ្រង់នេះប៉ុណ្ណោះ ទើបយើងប្រែក្លាយជាល្អឥតខ្ចោះដូចជាទ្រង់បាន។ សំរាប់មូលហេតុនេះ ការពិរោធរបស់ព្រះ និងសេចក្តីក្រោធរបស់ទ្រង់ គឺមិន*ផ្ទុយ* នឹងសេចក្តីស្រឡាញ់របស់ទ្រង់ទេ ប៉ុន្តែជា*ភស្តុតាង* មួយនៃសេចក្តីស្រឡាញ់របស់ទ្រង់។ ឪពុកម្តាយគ្រប់រូប ដឹងថា អ្នកអាចស្រឡាញ់កូនម្នាក់ដោយអស់ពីចិត្តទាំងស្រុង ខណៈពេលដែលមានកំហឹង ឬខកចិត្ត ចំពោះចរិតមិនល្អរបស់កូននោះ។

សេចក្តីស្រឡាញ់របស់ព្រះមានភាពធំធេងណាស់ រហូតបានធ្វើឱ្យផែនការដ៏ឥតខ្ចោះរបស់ទ្រង់បានប្រទានអំណោយទានជាច្រើនមកលើកូនចៅរបស់ទ្រង់ទាំងអស់ សូម្បីតែអ្នកទាំងឡាយដែលមិនគោរពតាមក្រិត្យវិន័យរបស់ទ្រង់។ ជីវិតរមែងស្លាប់គឺជាអំណោយមួយដែលបានប្រទានមកលើមនុស្សទាំងអស់ ដែលមានគុណសម្បត្តិនៅក្នុងសង្គ្រាមនៅស្ថានសួគ៌។6 អំណោយទានដែលគ្មានលក្ខខណ្ឌមួយទៀត គឺជាការរស់ឡើងវិញជាសាកលៈ "ព្រោះដូចជាមនុស្សទាំងអស់ បានត្រូវស្លាប់ក្នុងលោកអ័ដាមជាយ៉ាងណា នោះគ្រប់គ្នាក៏នឹងបានប្រោសឱ្យរស់ក្នុងព្រះគ្រីស្ទយ៉ាងនោះដែរ" (កូរិនថូសទី 1 15:22)។ អំណោយទានខាងជីវិតរមែងស្លាប់ដទៃទៀតជាច្រើន គឺមិនអាស្រ័យលើការគោរពប្រតិបត្តិផ្ទាល់ខ្លួនរបស់យើងចំពោះច្បាប់នោះទេ។ ដូចដែលព្រះយេស៊ូវបានបង្រៀនថា ព្រះវរបិតាសួគ៌យើងទ្រង់បាន "ធ្វើឱ្យថ្ងៃរបស់ទ្រង់រះឡើង បំភ្លឺទាំងមនុស្សអាក្រក់ និងមនុស្សល្អ ហើយបង្អុរឱ្យភ្លៀងធ្លាក់មកលើទាំងមនុស្សសុចរិត និងមនុស្សទុច្ចរិតផង" (ម៉ាថាយ 5:45)។

មានតែយើងនឹងស្តាប់ប៉ុណ្ណោះ ទើបយើងអាចដឹងពីសេចក្តីស្រឡាញ់របស់ព្រះ ហើយទទួលអារម្មណ៍សេចក្តីស្រឡាញ់នោះ សូម្បីតែនៅពេលយើងមិនគោរពប្រតិបត្តិក្តី។ មានស្ត្រីម្នាក់ថ្មី១នេះ បានត្រឡប់មកកាន់សកម្មភាពក្នុងសាសនាចក្រវិញ ដោយបានរៀបរាប់នៅក្នុងការនិយាយនៅម៉ោងសាក្រាម៉ង់ថាៈ "ទ្រង់តែងតែនៅជួយដល់ខ្ញុំជានិច្ច ទោះបីជាខ្ញុំបានបដិសេធទ្រង់ក្តី។ ទ្រង់តែងតែដឹកនាំខ្ញុំ ហើយលួងលោមចិត្តខ្ញុំដោយសេចក្តីករុណាដ៏ទន់ភ្លន់នៅជុំវិញខ្ញុំ ប៉ុន្តែខ្ញុំ[បាន]ខឹងខ្លាំងពេក ដែលមើលមិនឃើញ និងទទួលយកឧប្បត្តិហេតុ និងអារម្មណ៍ការគាំទ្រពីព្រះនោះ"។7

III.

ពរជ័យដ៏ជំរើសរបស់ព្រះ គឺអាស្រ័យទៅលើការគោរពប្រតិបត្តិចំពោះក្រិត្យវិន័យ និងបទបញ្ញត្តិទាំងឡាយរបស់ព្រះ យ៉ាងច្បាស់។ ការបង្រៀនដ៏សំខាន់គឺមានចេញមកពីវិវរណៈសម័យថ្មីថាៈ

"មានក្រិត្យវិន័យមួយដ៏ពុំអាចដកចេញបាន ដែលបានធ្វើនៅស្ថានសួគ៌មុនកំណើតលោកិយមកម្ល៉េះ ដែលគ្រប់ព្រះពរទាំងអស់ផ្អែកទៅលើ---

"ហើយកាលណាយើងបានព្រះពរណាមួយពីព្រះ នោះគឺដោយសារការគោរពដល់ក្រិត្យវិន័យនោះ ដែលព្រះពរនោះផ្អែកទៅលើ" (គ. និង ស. 130:20--21) ។

គោលការណ៍ដ៏មហិមានេះ ជួយយើងឱ្យយល់ពី*មូលហេតុ* ដែលរឿងជាច្រើន ដូចជាយុត្តិធម៌ និងសេចក្តីមេត្តាករុណា ត្រូវបានធ្វើឱ្យស្មើគ្នាតាមរយៈដង្វាយធួន ។ វាក៏បានពន្យល់ផងដែរថា ហេតុអ្វីព្រះនឹងមិនរារាំងការអនុវត្តន៍សិទ្ធិជ្រើសរើសរបស់កូនចៅទ្រង់ ។ សិទ្ធិជ្រើសរើស--- អំណាចរបស់យើងដើម្បីជ្រើសរើស--- គឺជាគ្រឹះចំពោះផែនការដំណឹងល្អ ដែលនាំយើងមកកាន់ផែនដី ។ ព្រះមិនធ្វើអន្តរាគមន៍ដើម្បីរារាំងលទ្ធផលនៃការជ្រើសរើសរបស់មនុស្សមួយចំនួន ដើម្បីការពារសុខុមាលភាពរបស់មនុស្សដទៃនោះទេ--- សូម្បីតែនៅពេលពួកគេសម្លាប់រងរបួស ឬជិះជាន់គ្នាទៅវិញទៅមកក្តី--- ត្បិតរឿងនេះនឹងបំផ្លាញផែនការទ្រង់សំរាប់ការរីកចំរើនដ៏អស់កល្បជានិច្ចរបស់យើង ។8 ទ្រង់នឹងប្រទានពរ យើងឱ្យស៊ូទ្រាំនឹងលទ្ធផលទាំងឡាយនៃការជ្រើសរើសរបស់អ្នកដទៃ ប៉ុន្តែទ្រង់នឹងមិនរារាំងការជ្រើសរើសទាំងនោះទេ ។9

បើសិនជាមនុស្សយល់អំពីការបង្រៀនរបស់ព្រះយេស៊ូវ នោះគាត់ ឬនាងមិនអាចសន្និដ្ឋានសមហេតុផលថា ព្រះវរបិតាសួគ៌ជាទីស្រឡាញ់របស់យើង ឬព្រះរាជបុត្រាដ៏ទេវភាពរបស់ទ្រង់ជឿថា សេចក្តីស្រឡាញ់របស់ពួកទ្រង់ អាចជំនួសបទបញ្ញត្តិរបស់ទ្រង់នោះទេ ។ ចូរពិចារណាអំពីគំរូទាំងនេះ ។

នៅពេលព្រះយេស៊ូវចាប់ផ្តើមការបំរើរបស់ទ្រង់ សារលិខិតដំបូងរបស់ទ្រង់ គឺអំពីការប្រែចិត្ត ។10

នៅពេលទ្រង់អនុវត្តសេចក្តីមេត្តាករុណាជាទីស្រឡាញ់ ដោយមិនកាត់ទោសដល់ស្ត្រីដែលប្រព្រឹត្តអំពើកំផិត ទោះជាយ៉ាងណាក៏ដោយ ទ្រង់បានប្រាប់ដល់នាងថា "អញ្ជើញទៅចុះ តែកុំធ្វើបាបទៀតឡើយ" (យ៉ូហាន 8:11) ។

ព្រះយេស៊ូវបានបង្រៀនថាៈ "មិនមែនអស់អ្នកណាដែលគ្រាន់តែនិយាយមកខ្ញុំថា ឱព្រះអម្ចាស់ៗអើយ ដែលនឹងចូលទៅក្នុងនគរស្ថានសួគ៌នោះទេ គឺជាអស់អ្នកដែលធ្វើតាមព្រះហឫទ័យនៃព្រះវរបិតា ដែលគង់នៅស្ថានសួគ៌វិញទេតើ" (ម៉ាថាយ 7:21) ។

ប្រសិទ្ធភាពនៃព្រះបញ្ញត្តិ និងក្រិត្យវិន័យទាំងឡាយរបស់ព្រះ មិនផ្លាស់ប្តូរ ដើម្បីតម្រូវទៅតាមអាកប្បកិរិយា ឬបំណងប្រាថ្នាដែលគេពេញនិយមឡើយ ។ បើសិនជានរណាម្នាក់គិតថា សេចក្តីស្រឡាញ់របស់ព្រះ ឬរបស់ឪពុកម្តាយចំពោះបុគ្គលម្នាក់ផ្តល់ជាការអនុញ្ញាតដល់មនុស្សជាទីស្រឡាញ់មិនឱ្យគោរពច្បាប់ នោះពួកគេមិនយល់អំពីសេចក្តីស្រឡាញ់ ហើយក៏មិនយល់អំពីច្បាប់ផងដែរ ។ ព្រះអម្ចាស់បានប្រកាសថាៈ "អ្វីក៏ដោយដែលបំពាក់ក្រិត្យវិន័យ ហើយមិននៅជាប់ក្នុងក្រិត្យវិន័យ ប៉ុន្តែស្វែងរកដើម្បីត្រឡប់ទៅជាក្រិត្យវិន័យ ដល់ខ្លួនគេវិញ ហើយព្រមនៅជាប់ក្នុងអំពើបាប ហើយនៅជាប់ជុំគ្នាក្នុងអំពើបាប នោះពុំអាចញែកចេញជាបរិសុទ្ធ ដោយសារក្រិត្យវិន័យបានឡើយឬដោយសារសេចក្តីមេត្តាករុណា សេចក្តីយុត្តិធម៌ ឬសេចក្តីជំនុំជំរះបានដែរ ។ ហេតុដូច្នេះហើយ ពួកគេត្រូវតែជាប់នៅក្នុងភាពស្មោគគ្រោកដដែល" (គ. និង ស. 88:35) ។

យើងអាននៅក្នុងវិវរណៈសម័យថ្មីថា "គ្រប់នគរទាំងអស់ត្រូវបានប្រទានក្រិត្យវិន័យឱ្យ" (គ. និង ស. 88:36) ។ ឧទាហរណ៍ៈ

"ត្បិតអ្នកណាដែលពុំអាចនៅជាប់ក្នុងក្រិត្យវិន័យនៃនគរសេឡេស្ទាលបានទេ នោះពុំអាចនៅជាប់ក្នុងសិរីល្អខាងសេឡេស្ទាលបានឡើយ ។

"ហើយអ្នកណាដែលពុំអាចនៅជាប់ក្នុងក្រិត្យវិន័យនៃនគរទេរេសទ្រាល នោះពុំអាចនៅជាប់ក្នុងសិរីល្អខាងទេរេសទ្រាលបានឡើយ ។

"ហើយអ្នកណាដែលពុំអាចនៅជាប់ក្នុងក្រិត្យវិន័យនៃនគរទេឡេស្ទាលបានទេ នោះពុំអាចនៅជាប់ក្នុងសិរីល្អខាងទេឡេស្ទាលបានឡើយ" (គ. និង ស. 88:22--24) ។

ម្យ៉ាងវិញទៀត នគរនៃសិរីល្អដែលការជំនុំជំរះចុងក្រោយនឹងរៀបចំឱ្យយើងនោះ មិនមែនត្រូវបានកំណត់ដោយសេចក្តីស្រឡាញ់ទេ ប៉ុន្តែដោយក្រិត្យវិន័យដែលព្រះបានប្រើប្រាស់នៅក្នុងផែនការរបស់ទ្រង់ ដើម្បីធ្វើឱ្យយើងមានភាពសក្តិសមសំរាប់ជីវិតដ៏អស់កល្បជានិច្ច "គឺជាអំណោយទានដ៏មហិមាបំផុតនូវគ្រប់អំណោយទានទាំងឡាយនៃព្រះ" (គ. និង ស. 14:7) ។

IV.

នៅក្នុងការបង្រៀន និងការប្រតិកម្មចំពោះកូនចៅរបស់ខ្លួន ឪពុកម្តាយមានឱកាសជាច្រើន ដើម្បីអនុវត្តគោលការណ៍ទាំងនេះ ។ ឱកាសមួយគឺមានជាប់ទាក់ទងទៅនឹងអំណោយទានទាំងឡាយ ដែលឪពុកម្តាយផ្តល់ទៅឱ្យកូនរបស់ពួកគេ ។ ដូចជាព្រះបានប្រទានអំណោយទានមួយចំនួន ទៅដល់កូនចៅនៅជីវិតរមែងស្លាប់របស់ទ្រង់ទាំងអស់ ដោយមិនតំរូវឱ្យ ពួកគេមានការប្រតិបត្តិផ្ទាល់ចំពោះក្រិត្យវិន័យរបស់ទ្រង់ឡើយ ដូច្នេះឪពុកម្តាយផ្តល់អត្ថប្រយោជន៍ជាច្រើន ដូចជាផ្ទះ សម្លៀង និងម្ហូបអាហារ ទោះបីជាកូនរបស់ពួកគាត់មិនចុះសម្រុងទាំងស្រុង ចំពោះតំរូវការទាំងអស់ របស់ឪពុកម្តាយក្តី ។ ប៉ុន្តែនៅខាងក្រោមនេះ មាននូវឧទាហរណ៍របស់ព្រះវរបិតាសួគ៌ជាទីស្រឡាញ់ និងមានគ្រប់ប្រាជ្ញាដែលបានប្រទាន ក្រិត្យវិន័យ និងបទបញ្ញត្តិ សំរាប់ជាប្រយោជន៍ដល់កូនចៅរបស់ទ្រង់ ឪពុកម្តាយវ័យឆ្លាតដាក់លក្ខខណ្ឌអំណោយទាន ជាឪពុកម្តាយមួយចំនួន ទៅលើការគោរពប្រតិបត្តិ ។

បើឪពុកម្តាយមានកូនដែលចចេស--- ដូចជាយុវវ័យដែលប្រើជាតិស្រវឹង ឬថ្នាំញៀន--- ពួកគេប្រឈមមុខនឹងសំណួរដ៏ធ្ងន់ធ្ងរមួយ ។ តើសេចក្តីស្រឡាញ់របស់ឪពុកម្តាយ តំរូវឱ្យសារធាតុទាំងនេះ ឬការប្រើប្រាស់របស់ទាំងនោះ អាចចូលមកគេហដ្ឋានឬ ឬក៏តំរូវការនៃច្បាប់ស៊ីវិល ឬការប្រព្រឹត្តធ្ងន់ធ្ងរ ឬចំណាប់អារម្មណ៍របស់កូន១ដទៃទៀតនៅក្នុងផ្ទះ តំរូវឱ្យមានការហាមឃាត់ដល់រឿងនេះ?

សំណួរកាន់តែធ្ងន់ធ្ងរមួយទៀតសួរថា បើសិនជាកូនពេញវ័យកំពុងតែរស់នៅជាមួយនឹងដៃគូរបស់គេដោយគ្មានរៀបការ តើទំនាក់ទំនងខាងផ្លូវភេទធ្ងន់ធ្ងរក្រៅចំណងអាពាហ៍ពិពាហ៍នេះ តំរូវឱ្យកូននេះមានអារម្មណ៍ថា គ្មានការអនុញ្ញាតពី ក្រុមគ្រួសារយ៉ាងខ្លាំងដោយឈប់ទាក់ទងនឹងសមាជិកគ្រួសារ ឬតើសេចក្តីស្រឡាញ់របស់ឪពុកម្តាយ តំរូវឱ្យមិនអើពើរ នឹងដៃគូដែលមិនបានរៀបការនេះ? ខ្ញុំបានមើលឃើញប្រតិកម្មយ៉ាងខ្លាំងទាំងពីរនេះ ហើយជឿថា រឿងទាំងពីរនេះគឺជា រឿងមិនសមរម្យ ។

តើប្រតិកម្មសមរម្យរបស់ឪពុកម្តាយមានអ្វីខ្លះ? នេះគឺជារឿងសំខាន់សំរាប់ឪពុកម្តាយឆ្លាតវៃ ដែលបានដឹកនាំដោយការបំផុសគំនិតពីព្រះអម្ចាស់។ គ្មានតំបន់ណាសំរាប់ទង្វើរបស់ឪពុកម្តាយ ដែលមានតំរូវការជាងការណែនាំពីស្ថានសួគ៌ ឬហាក់ដូចជាដើម្បីទទួលវាច្រើនជាងការសម្រេចចិត្តរបស់ឪពុកម្តាយ នៅក្នុងការចិញ្ចឹមបីបាច់កូនចៅរបស់ពួកគេ និងគ្រប់គ្រងក្រុមគ្រួសាររបស់ពួកគេនោះទេ។ នេះគឺជាកិច្ចការនៃភាពអស់កល្បជានិច្ច។

នៅពេលឪពុកម្តាយ ស្មុគស្មាញជាមួយនឹងបញ្ហាទាំងនេះ ពួកគាត់គួរតែចងចាំដល់ការបង្រៀនរបស់ព្រះអម្ចាស់ថា យើងទុកចោលចៀមកៅសិបប្រាំបួន ហើយចេញទៅក្នុងទីរហោស្ថានដើម្បីសង្គ្រោះដល់ចៀមដែលវង្វេងបាត់។11 ប្រធាន ថូម៉ាស អេស ម៉នសុនបានអំពាវនាវរកបេសកកម្មនៃសេចក្តីស្រឡាញ់ដើម្បីសង្គ្រោះ... បងប្អូនប្រុសស្រីរបស់យើងដែលវង្វេងនៅក្នុងទីរហោស្ថាននៃភាពខ្ជិលច្រអូស ឬភាពព្រងើយកន្តើយ។12 ការបង្រៀនទាំងនេះ តំរូវឱ្យមានការស្រឡាញ់ខ្វល់ខ្វាយជាបន្តបន្ទាប់ ដែលទាមទារឱ្យមានទំនាក់ទំនងដោយក្តីស្រឡាញ់ពិតជាប់ជានិច្ច។

ឪពុកម្តាយគួរតែចងចាំផងដែរពី ការបង្រៀនជាញឹកញាប់របស់ព្រះអម្ចាស់ថា "អ្នកណាដែលយើងស្រឡាញ់ នោះយើងវាយ ផ្ចាល" (ហេព្រើរ 12:6)។13 នៅក្នុងប្រសាសន៍សន្និសីទរបស់លោកអំពីការអត់អោន និងសេចក្តីស្រឡាញ់ អែលឌើរ រ័សុល អិម ណិលសុន បានបង្រៀនថា "សេចក្តីស្រឡាញ់ពិតចំពោះមនុស្សប្រព្រឹត្តអំពើបាប អាចប្រឈមមុខបង្គាប់ដោយក្លាហាន--- ពុំមែនដោយស្រុះស្រួលទៅតាមទេ! សេចក្តីស្រឡាញ់ពិតមិនគាំទ្រដល់អាកប្បកិរិយាបំផ្លាញខ្លួនឯងនោះឡើយ" ។14

មិនថាមនុស្សមានប្រតិកម្មយ៉ាងណាចំពោះអំពើបាបទេ អាស្រ័យទៅលើភាពតានតឹងរវាងអំណាចនៃសេចក្តីស្រឡាញ់ និងច្បាប់ការបំបាក់បទបញ្ញត្តិ គឺមានឥទ្ធិពលយ៉ាងច្បាស់ទៅលើទំនាក់ទំនងក្នុងគ្រួសារ។ ព្រះយេស៊ូវបានបង្រៀនថា:

"តើអ្នករាល់គ្នាស្មានថា ខ្ញុំមកដើម្បីឱ្យមានសេចក្តីសុខសាន្តនៅផែនដីឬអី? ខ្ញុំប្រាប់អ្នករាល់គ្នាថា មិនមែនទេ គឺមកដើម្បីឱ្យកើត

"ត្បិតពីនេះទៅមុខនឹងមានប្រាំនាក់នៅក្នុងផ្ទះមួយបាក់បែកគ្នា គឺបីនាក់ទាស់នឹងពីនាក់ ហើយពីរនាក់ទាស់នឹងបីនាក់។

"ឯឪពុកនឹងបាក់បែកទាស់នឹងកូនប្រុស ហើយកូនប្រុសទាស់នឹងឪពុក ម្តាយទាស់នឹងកូនស្រី ហើយកូនស្រីទាស់នឹងម្តាយ ម្តាយក្មេកទាស់នឹងកូនប្រសារស្រី" (លូកា 12:51--53)។

ការបង្រៀនដ៏ខ្សឹកខ្សួលនេះរំលឹកយើងថា នៅពេលសមាជិកគ្រួសារគ្មានសាមគ្គីភាពនៅក្នុងការខិតខំរក្សាព្រះបញ្ញត្តិទាំងឡាយរបស់ព្រះ នោះនឹងមានការបាក់បែក។ យើងធ្វើឱ្យអស់ពីលទ្ធភាពរបស់យើង ដើម្បីចៀសវាងពីការបែកបាក់ទំនាក់ទំនងសេចក្តីស្រឡាញ់ ប៉ុន្តែពេលខ្លះវាកើតឡើង ទោះជាយើងបានខិតខំអស់សមត្ថភាពហើយក្តី។

នៅកណ្តាលភាពស្មុគស្មាញដូច្នេះ យើងត្រូវតែស៊ូទ្រាំនឹងភាពពិតថា ការវង្វេងចេញរបស់មនុស្សជាទីស្រឡាញ់នៃយើងនឹងបង្ខូចដំណើរសុភមង្គលរបស់យើងមែន ប៉ុន្តែវាមិនគួរបង្ខូចដល់សេចក្តីស្រឡាញ់របស់យើងចំពោះគ្នាទៅវិញទៅមក នោះទេ ឬបង្ខូចដល់

ការខិតខំអត់ធ្មត់របស់យើងដើម្បីមានសាមគ្គីភាពនៅក្នុងការយល់ដឹងអំពីសេចក្ដីស្រឡាញ់របស់ព្រះ និងក្រិត្យវិន័យរបស់ព្រះនោះទេ ។

ខ្ញុំថ្លែងទីបន្ទាល់អំពីសេចក្ដីពិតនៃរឿងទាំងនេះ ដែលផ្នែកមួយនៃផែនការសង្គ្រោះ និងជាគោលលទ្ធិនៃព្រះគ្រីស្ទ ជាអង្គដែលខ្ញុំសូមធ្វើទីបន្ទាល់ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. សូមមើល រ័សុល អិម ណិលសុន "Divine Love" *Liahona* ខែ កុម្ភៈ ឆ្នាំ 2003 ទំព័រ 12 ។

2. សូមមើល អាលម៉ា 42:25 ។

3. សូមមើល ឧទាហរណ៍ ពួកចៅហ្វាយ 2:12--14; ទំនុកដំកើង 7:11 គ. និង ស. 5:8, 63:32 ។

4. សូមមើល ឧទាហរណ៍ ពង្សាវតាក្សត្រទី 2 23:26--27 អេភេសូរ 5:6 នីហ្វៃទី 1 22:16--17 អាលម៉ា 12:35--36; គ. និង ស. 84:24 ។

5. *Teachings of Presidents of the Church: Joseph Smith* ( ឆ្នាំ 2007 ) ទំព័រ 210 ។

6. សូមមើល វិវរណៈ 12:7--8 ។

7. សំបុត្រថ្ងៃទី 6 ខែ ធ្នូ ឆ្នាំ 2005 នៅក្នុងកម្មសិទ្ធិរបស់អ្នកនិពន្ធ ។

8. ប្រៀបធៀប អាលម៉ា 42:8 ។

9. ប្រៀបធៀប ម៉ូសាយ 24:14--15 ។

10. សូមមើល ម៉ាថាយ 4:17 ។

11. សូមមើល លូកា 15:3--7 ។

12. សូមមើល ថូម៉ាស អេស ម៉នសុន "Lost Battalions" *Liahona* ខែ កញ្ញា ឆ្នាំ 1987 ទំព័រ 3 ។

13. សូមមើល សុភាសិត 3:12 វិវរណៈ 3:19 គ. និង ស. 95:1 ផងដែរ ។

10. រ័សុល អិម ណិលសុន "Teach Us Tolerance and Love" *Ensign* ខែ ឧសភា ឆ្នាំ 1994 ទំព័រ 71 ។